**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:២៤៩ប្រ
ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០២
**សាលដីកា**
លេខ:១៦២
ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក ............. ជាចៅក្រមរបាយការណ៍
៤-លោក ............... ជាចៅក្រម
៥-លោក ................. ជាចៅក្រម

**ក្រឡាបញ្ជី**

-លោកស្រី .............

**តំណាងមហាអយ្យការ**

-លោក ............... ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ២៩"ក" ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៩៧ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះងសបរ(ជាចុងបណ្តឹងសាទុក្ខ)ភេទប្រុសអាយុ៤១ឆ្នាំ ជាតិខ្មែរមុខរបរធ្វើការក្រសួងពត៌មាន ទីលំនៅសព្វថ្ងៃផ្ទះលេខ២៥០ មណ្ឌល១៨ ភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះង៉ែត សំអុល "ស" ម្តាយឈ្មោះមុំ គឹមសាន "ស" ។

ចុងចម្លើយឈ្មោះវគ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរទីលំនៅសព្វថ្ងៃផ្ទះលេខ២៥០ មណ្ឌល១៨ ភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ ក្រុងភ្នំពេញ។

**កម្មវត្ថុបណ្តឹង:** ប្តឹងសុំកិច្ចការប្រញាប់

បានឃើញបណ្តឹងសាទុក្ខលេខ១៧៧ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០២ របស់ឈ្មោះវគ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២៩"ក" ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសេចក្តីសម្រេច នៃសាលដីកាទាំងមូល។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២៤ប្រ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០២ របស់តុលាការកំពូល។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៥-៥-១៩៩៩ របស់ឈ្មោះងសបរ ប្តឹងសុំកិច្ចការប្រញាប់ហាមឃាត់ឈ្មោះ វ៉ា គី និងក្រុមគ្រួសារមិនឱ្យលក់ដូរ ជួល បញ្ចាំ ផ្ទេរសិទ្ធិ ធ្វើអំណោយសាងសង់រំលាយធ្វើជា ផ្លូវដើរកាត់នៅលើទីតាំងដីទំនាស់ខាងត្បូង ឈៀងខាងកើតផ្ទះវ៉ា គី លេខ២៥០ មណ្ឌលទី១៨ ភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ទំហំដី ៥មx៧ម និងដីល្វែងក្រោមផ្ទះរបស់វ៉ា គី នៅជាប់ព្រំល្វែងក្រោមផ្ទះរបស់ខ្លួនទំហំ៧មx២.៥ម ជាបណ្តោះអាសន្ន ដើម្បីជានាដល់ការសម្រេចអង្គសេចក្តី និងការអនុវត្តន៍សាលក្រមរបស់តុលាការ ។

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ០៣ប្រ"យ" ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹង ចុះថ្ងៃទី០៥-៥-១៩៩៩ របស់ដើមចោទឈ្មោះង៉ែត សេប៉ូរ៉ាក់ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២-ហាមឃាត់ឈ្មោះវគ និងក្រុមគ្រួសារមិនឱ្យលក់-ដូរ-ជួល-បញ្ចាំ ផ្ទេរសិទ្ធិ ធ្វើអំណោយសាងសងទំលាយធ្វើជាផ្លូវដើរកាត់នៅលើទីតាំងដីទំនាស់ខាងត្បូងឈៀងខាងកើតផ្ទះវ៉ា គី មណ្ឌលទី១៨ ភូមិកណ្តាល សង្កាត់ច្បារអំពៅទី២ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ទំហំ៥ម៉ែត្រ គុណ៧ម៉ែត្រ និងក្រោមរបស់វ៉ា គី ដែលនៅជាប់ព្រំល្វែងក្រោមផ្ទះរបស់ខ្លួនទំហំ ៧ម៉ែត្រ គុណ ២,៥ម៉ែត្រ ជាបណ្តោះអាសន្នសិន រង់ចាំតុលាការសម្រេចដល់រឿងអង្គសេចក្តី ។

៣-បង្គាប់ឱ្យឈ្មោះង៉ែត សេប៉ូរ៉ាក់ បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង១៨០០៛ និងរង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់២០០៛ ដែលដើមចោទបានបង់ទុករួចជាស្រេច ។

៤-ដីកានេះមានអានុភាពអនុវត្តភ្លាមៗ ទោះបីជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

៥-ដីកាសម្រេចនេះ ជំនុំជំរះជាសាធារណៈចំពោះមុខដើមចោទ ចុងចម្លើយសម្រេចបើកផ្លូវ ប្តឹងឧទ្ធរណ៍កំណត់៦០ថ្ងៃ គិតចាប់តាំងពីថ្ងៃសម្រេចដីកានេះ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ០១"យ" ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៩ របស់ឈ្មោះវ៉ា គី ប្តឹងមិនសុខចិត្តនឹងដីកាសម្រេចកិច្ចការប្រញាប់លេខ០៣"យ" ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ២៩"ក" ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-មិនទទួលជំនុំជំរះ ដីកាសម្រេចកិច្ចការប្រញាប់លេខ០៣ប្រ"យ" ចុះថ្ងៃទី១០-០៥-១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដោយរឿងអង្គសេចក្តី បានចូលស្ថាពរហើយ ។

២-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទ បើកសិទ្ធិឱ្យប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ១៧៧ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០២ របស់ឈ្មោះវ៉ា គី ប្តឹង មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២៩"ក" ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្តីសម្រេចនៃសាលដីកាទាំងមូល ។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា៖ បណ្តឹងសាទុក្ខរបស់ចុងចម្លើយស្ថិតនៅ ក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះមកពិនិត្យពិចារណា ។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេច។

-បានស្តាប់ចម្លើយរបស់ឈ្មោះវ៉ា គី នាពេលសវនាការថា៖ បានជាខ្លួនប្តឹងសាទុក្ខមកតុលាការកំពូលមកពីសាលាឧទ្ធរណ៍កាត់ក្តីឱ្យខ្លួនដោយអយុត្តិធម៌បំផុតពីព្រោះគាត់បានរំលោភបំពានយកដីរបស់ខ្លួនព្រមទាំងយកកម្លាំងប៉ូលីសនិងទាហាន មកគម្រាមកំហែងខ្លួនពីរបីឡាន អាងគាត់បងប្អូនម៉ក់ ជីភូ គាត់ជាអ្នកសុំខ្លួនឱ្យដើមចោទស្នាក់នៅ ។

ហើយរឿងនេះ ពួកគេបានចុះទៅអនុវត្តសាលដីកា របស់សាលាឧទ្ធរណ៍ ដោយគេនិយាយថា រឿងនេះចប់នៅសាលាឧទ្ធរណ៍ ហើយពេលចុះទៅអនុវត្តនោះ មិនបានសម្រេចទេ ដោយខ្លួនមិនព្រមឱ្យអនុវត្ត ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់អ្នកស្រី វា គី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៧៧ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០២ របស់អ្នកស្រីវា គី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានដោយយោងតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា រឿងអង្គសេចក្តីក្នុងរឿងនេះ បានចប់ជាស្ថាពរ តាមសាលដីការដ្ឋប្បវេណីលេខ១៧៤"ឈ" ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១ ។ ដូច្នេះរឿងក្តីកិច្ចការប្រញាប់ដែលជាវិធានការបណ្តោះអាសន្នមុនរឿងអង្គសេចក្តី តុលាការពុំគប្បីលើកមកពិចារណាឡើយ ។

-យល់ឃើញថា ដើមចោទបានទទួលដំណឹងពីដីកាកោះឱ្យមកចូលរួមនាសវនាការនេះហើយ ប៉ុន្តែពុំបានមកចូលរួមទេ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ២៩"ក" ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទម្រង់ ទាំងគតិច្បាប់ ។

### ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តីចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ១៧៧ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០២ របស់អ្នកស្រីវា គី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស នឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ២៩"ក" ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ ដែលអ្នកស្រីវា គី បានបង់ទុកនៅតុលាការកំពូលគឺ ៖

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥០០០៛ សរុប១៩០០០៛ ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០០៤ ។